ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍

## បូកសរុបលទ្ធផលការងារត្រីមាសទី១ ឆ្នាំ២០២២
## និងទិសដៅអនុវត្តបន្ត

រៀបចំដោយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

# មាតិកា


**មាតិកា** ..... i

**បញ្ជីតារាង** ..... iii

I.**លទ្ធផលការងារ** ..... 1

**កម្មវិធីទី១.** ***ការបង្កើនប្រសិទ្ធភាពសេវាសុខុមាលភាពសង្គម*** ..... 1

**អនុកម្មវិធីទី១.១.ការអភិវឌ្ឍសុខុមាលភាពសម្រាប់ជនរងគ្រោះនិងងាយរងគ្រោះ និងកិច្ចការគ្រួសារ** ..... 1

**អនុកម្មវិធីទី១.២.ការអភិវឌ្ឍសុខុមាលភាពកុមារ និងយុវនីតិសម្បទា** ..... 3

**អនុកម្មវិធីទី១.៣.ការអភិវឌ្ឍសុខុមាលភាពជនពិការ** ..... 5

**អនុកម្មវិធីទី១.៤.ការអភិវឌ្ឍសុខុមាលភាពមនុស្សចាស់** ..... 6

**អនុកម្មវិធីទី១.៥.ការអភិវឌ្ឍសុខុមាលភាពអតីតយុទ្ធជន** ..... 6

**កម្មវិធីទី២.** ***ការបង្កើនប្រសិទ្ធភាពប្រព័ន្ធសន្តិសុខសង្គម និងផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាជនពិការ*** ..... 6

**អនុកម្មវិធីទី២.១.ការបង្កើនប្រសិទ្ធភាពសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល** ..... 6

**អនុកម្មវិធីទី២.២.ការបង្កើនប្រសិទ្ធភាពសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន និងគ្រួសារ** ..... 7

**អនុកម្មវិធីទី២.៣.ការបន្តនិរន្តរភាពការផ្តល់សេវាស្តារលទ្ធភាពពលកម្មជូនជនពិការ** ..... 8

**កម្មវិធីទី៣.** ***ការពង្រឹងសមត្ថភាពស្ថាប័ននិងអភិវឌ្ឍភាពជាដៃគូ*** ..... 9

**អនុកម្មវិធីទី៣.១.ការពង្រឹងសមត្ថភាពស្ថាប័ន និងភាពជាដៃគូ** ..... 9

**អនុកម្មវិធីទី៣.២.ការអភិវឌ្ឍធនធានមនុស្ស** ..... 9

II-**ទិសដៅអនុវត្តបន្ត** ..... 10

**កម្មវិធីទី១.ការបង្កើនប្រសិទ្ធភាពសេវាសុខុមាលភាពសង្គម** ..... 10

**អនុកម្មវិធីទី១.១.ការអភិវឌ្ឍសុខុមាលភាពសម្រាប់ជនរងគ្រោះនិងងាយរងគ្រោះ** ..... 10

**និងកិច្ចការគ្រួសារ** ..... 10

**អនុកម្មវិធីទី១.២.ការអភិវឌ្ឍសុខុមាលភាពកុមារ និងយុវនីតិសម្បទា** ..... 10

**អនុកម្មវិធីទី១.៣.ការអភិវឌ្ឍសុខុមាលភាពជនពិការ** ..... 11

**អនុកម្មវិធីទី១.៤.ការអភិវឌ្ឍសុខុមាលភាពមនុស្សចាស់** ..... 12

អនុកម្មវិធីទី១.៥.ការអភិវឌ្ឍសុខុមាលភាពអតីតយុទ្ធជន ........ 12
កម្មវិធីទី២.ការបង្កើនប្រសិទ្ធិភាពប្រព័ន្ធសន្តិសុខសង្គម និងផ្តល់សេវាស្តារលទ្ធភាព ........ 12
ពលកម្មកាយសម្បទាជនពិការ ........ 12
អនុកម្មវិធីទី២.១.ការបង្កើនប្រសិទ្ធភាពសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់ ........ 12
មន្ត្រីរាជការស៊ីវិល ........ 12
អនុកម្មវិធីទី២.២.ការបង្កើនប្រសិទ្ធភាពសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់ ........ 12
អតីតយុទ្ធជន និងគ្រួសារ ........ 12
អនុកម្មវិធីទី២.៣.ការបន្តនិរន្តរភាពការផ្តល់សេវាស្តារលទ្ធភាពពលកម្មជូនជនពិការ ........ 12
កម្មវិធីទី៣.ការពង្រឹងសមត្ថភាពស្ថាប័ននិងអភិវឌ្ឍភាពជាដៃគូ ........ 13
អនុកម្មវិធីទី៣.១.ការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងភាពជាដៃគូ ........ 13
អនុកម្មវិធីទី៣.២.ការអភិវឌ្ឍធនធានមនុស្ស ........ 13

# បញ្ជីតារាង


តារាងទី១៖ ជំនួយសង្គ្រោះបន្ទាន់ដល់ក្រុមជនរងគ្រោះ និងងាយរងគ្រោះ ........................................ 1

តារាងទី២៖ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ០-២ឆ្នាំ ទទួលបានប្រាក់ឧបត្ថម្ភកម្មវិធីត្រីមាស ឆ្នាំ២០២២ ........ 2

តារាងទី៣៖ ការឧបត្ថម្ភរបស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជូនមណ្ឌលកុមារកំព្រា........................ 3

តារាងទី៤ ៖ ចំនួនជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀននៅតាមមជ្ឈមណ្ឌល ...................................... 5

តារាងទី៥៖ ទិន្នន័យធ្វើបច្ចុប្បន្នភាពសិទ្ធិវន្តរបស់ ប.ជ.ស. ក្នុងត្រីមាសទី១ ឆ្នាំ២០២២ ............................................ 6

តារាងទី៦៖ ទិន្នន័យសរុបរបស់សិទ្ធិវន្តដែលធ្វើបច្ចុប្បន្នភាពគិតត្រឹមខែមីនា ឆ្នាំ២០២២............................................ 7

តារាងទី៧៖ ទិន្នន័យសិទ្ធិវន្តនៃ ប.ជ.ស. ដែលកំពុងបើករបបតាមប្រព័ន្ធធនាគារ ក្នុងខែមីនា ឆ្នាំ២០២២................ 7

តារាងទី៨៖ កំណត់ប្រាក់របបសន្តិសុខសង្គមជូនអតីតយុទ្ធជន និងគ្រួសារក្នុងត្រីមាសទី១ ឆ្នាំ២០២២ .................... 7

តារាងទី៩៖ លុបឈ្មោះអតីតយុទ្ធជនដែលទទួលមរណភាព និងទទួលស្គាល់ជាជនពលី និងមរណៈវិញ .................. 7

តារាងទី១០៖ លុបឈ្មោះអតីតយុទ្ធជន និងគ្រួសារចេញពីបញ្ជីបើកប្រាក់ក្នុងត្រីមាសទី១ ឆ្នាំ២០២២ ....................... 7

តារាងទី១១៖ អតីតយុទ្ធជន និងគ្រួសារដែលកំពុងទទួលប្រាក់របបសន្តិសុខសង្គមក្នុងខែមីនា ឆ្នាំ២០២២.............. 8

# របាយការណ៍
## បូកសរុបលទ្ធផលការងារត្រីមាសទី១ ឆ្នាំ ២០២២ និងទិសដៅអនុវត្តបន្ត

ផ្អែកលើយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ចតុកោណទី១ "ការអភិវឌ្ឍធនធានមនុស្ស" ត្រង់មុំទី៤៖ ការពង្រឹងសមភាពយេនឌ័រ និងកិច្ចគាំពារសង្គម ដើម្បីលើកស្ទួយស្ថានភាពសង្គម សេដ្ឋកិច្ច និងពង្រឹងតួនាទីស្ត្រី ដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និងសង្គមជាតិ បានបង្ហាញយ៉ាងច្បាស់អំពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ក្នុងការជួយដល់ជនរងគ្រោះ និងងាយរងគ្រោះគ្រប់ប្រភេទក្នុងសង្គម ជាពិសេស កុមារកំព្រា កុមារងាយរងគ្រោះ ស្ត្រី ជនចាស់ជរា ជនពិការ អតីតយុទ្ធជន និងអតីតមន្ត្រីរាជការស៊ីវិល។

ក្នុងគោលបំណងពង្រឹងនូវបណ្តាញសុវត្ថិភាពសង្គម និងកិច្ចគាំពារសង្គម រួមចំណែកក្នុងការលើកកម្ពស់សុខុមាលភាពរបស់ប្រជាជន ជាពិសេស ជនរងគ្រោះ និងងាយរងគ្រោះ ឱ្យរួចផុតពីហានិភ័យទាំងឡាយ ក្រសួង ស.អ.យ. បានដាក់ចេញនូវផែនការយុទ្ធសាស្ត្រ ២០១៩-២០២៣ ផ្តោតលើកម្មវិធីសំខាន់ៗចំនួនបីគឺ១.ការបង្កើនប្រសិទ្ធភាពសេវាសុខុមាលភាពសង្គម ២.ការបង្កើនប្រសិទ្ធភាពប្រព័ន្ធសន្តិសុខសង្គមនិងផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាជនពិការ និង៣.ការពង្រឹងសមត្ថភាពស្ថាប័ន និងអភិវឌ្ឍភាពជាដៃគូ។ អនុកម្មវិធី ១២ រួមមាន ១.ការអភិវឌ្ឍសុខុមាលភាពសម្រាប់ជនរងគ្រោះនិងងាយរងគ្រោះ និងកិច្ចការគ្រួសារ ២.ការអភិវឌ្ឍសុខុមាលភាពកុមារនិងយុវនីតិសម្បទា ៣.ការអភិវឌ្ឍសុខុមាលភាពជនពិការ ៤.ការអភិវឌ្ឍសុខុមាលភាពមនុស្សចាស់ ៥.ការអភិវឌ្ឍសុខុមាលភាពអតីតយុទ្ធជន ៦.ការបង្កើនប្រសិទ្ធភាពសេវាសុខុមាលភាពសង្គមរាជធានី ខេត្ត ៧.ការបង្កើនប្រសិទ្ធភាពសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ៨.ការបង្កើនប្រសិទ្ធភាពសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន ៩.ការបន្តនិរន្តរភាពការផ្តល់សេវាស្តារលទ្ធភាពពលកម្មជូនជនពិការ ១០.ការពង្រឹងសមត្ថភាពស្ថាប័ននិងភាពជាដៃគូ ១១.ការអភិវឌ្ឍធនធានមនុស្ស និង១២.ការពង្រឹងសមត្ថភាពស្ថាប័ននិងអភិវឌ្ឍភាពជាដៃគូរាជធានី ខេត្ត។

ជាអាទិ៍ក្នុងត្រីមាសទី១ ឆ្នាំ២០២២នេះ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាអនុវត្តសម្រេចបានលទ្ធផលដូចខាងក្រោម៖

**I.លទ្ធផលការងារ**

***កម្មវិធីទី១.ការបង្កើនប្រសិទ្ធភាពសេវាសុខុមាលភាពសង្គម***

-រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យស្តីពីការបង្កើតមូលនិធិជាតិជំនួយសង្គមជាគ្រឹះស្ថានសាធារណៈរដ្ឋបាល កាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ ក្នុងគោលបំណងអនុវត្តកិច្ចគាំពារសង្គមសម្រាប់ជនរងគ្រោះ និងងាយរងគ្រោះ។

**អនុកម្មវិធីទី១.១.ការអភិវឌ្ឍសុខុមាលភាពសម្រាប់ជនរងគ្រោះនិងងាយរងគ្រោះ និងកិច្ចការគ្រួសារ**

**១.១.១.ការងារសង្គ្រោះបន្ទាន់ដល់ក្រុមជនរងគ្រោះ និងងាយរងគ្រោះ**

-បានផ្តល់ជំនួយសង្គ្រោះបន្ទាន់ជាស្បៀង និងសម្ភារផ្សេងៗដល់ប្រជាជនរងគ្រោះ និងងាយរងគ្រោះ ៣ ៩៧៨គ្រួសារ

តារាងទី១៖ ជំនួយសង្គ្រោះបន្ទាន់ដល់ក្រុមជនរងគ្រោះ និងងាយរងគ្រោះ

| ល.រ | រាជធានី/ខេត្ត | ជំនួយសង្គ្រោះ (គ្រួសារ) |
|---|---|---|
| ១ | ក្រសួង | ៧៤ |
| ២ | កំពង់ស្ពឺ | ០៥ |
| ៣ | ស្ទឹងត្រែង | ៣០២ |
| ៤ | បន្ទាយមានជ័យ | ២ ០៩៩ |
| ៥ | ក្រចេះ | ១០៥ |
| ៦ | កែប | ៧ |
| ៧ | ពោធិ៍សាត់ | ៤២ |
| ៨ | មណ្ឌលគិរី | ៤០៣ |
| ៩ | កោះកុង | ១៥៥ |
| ១០ | កំពង់ចាម | ៦៨៣ |
| ១១ | ស្វាយរៀង | ១០៣ |
| | សរុប | ៣ ៩៧៨ |

### ១.១.២.ការងារជនអនាថា

-បានទទួលជនអនាថា ៤៧៨នាក់ ក្នុងនោះរាជធានីភ្នំពេញ ៤៦៨នាក់ និងខេត្តកំពង់ចាម ១០នាក់ មកពិគ្រោះយោបល់ អប់រំ និងបញ្ជូនទៅទទួលសេវាបន្តនៅមណ្ឌលសំចតសង្គមកិច្ចរាជធានីភ្នំពេញ និងមណ្ឌលរបស់អង្គការដៃគូ និងបានធ្វើសមាហរណកម្មទៅសហគមន៍វិញ ៥០នាក់ ក្នុងនោះ រាជធានីភ្នំពេញ ៣០នាក់ ខេត្តព្រះសីហនុ ១២នាក់ កំពង់ចាម ០៤នាក់ និងខេត្តប៉ៃលិន ០៤នាក់

-មជ្ឈមណ្ឌលជនវិបល្លាសស្មារតីស្ថិតនៅភូមិបាត្ត ឃុំបាត្ត ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាលបានទទួលជនវិបល្លាសស្មារតីឱ្យស្នាក់នៅចំនួន ៨៥នាក់។

### ១.១.៣.ការងារគ្រួសារ និងយេនឌ័រ

-គិតពីថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១៩ ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ រដ្ឋាភិបាលបានផ្ដល់ប្រាក់ឧបត្ថម្ភជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ០២ឆ្នាំសរុបចំនួន ២៦០ ២៤៨នាក់ ដោយបានចំណាយថវិកាសរុប ៦៩ ៦៥៩ ៧៦០ ០០០៛។ ដោយឡែក បើគិតក្នុងត្រីមាសទី១ ឆ្នាំ២០២២ រដ្ឋាភិបាលបានផ្ដល់ប្រាក់ឧបត្ថម្ភជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ០២ឆ្នាំសរុបចំនួន ១៣ ១១២នាក់ ដោយចំណាយថវិកាសរុបចំនួន ៧ ៩១០ ២៨០ ០០០៛

តារាងទី២៖ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ០២ឆ្នាំ ទទួលបានប្រាក់ឧបត្ថម្ភកម្មវិធីក្នុងត្រីមាសទី១ ឆ្នាំ២០២២

| ល.រ | រាជធានី/ខេត្ត | អ្នកទទួលផល (នាក់) | | | ថវិកា (៛) |
|---|---|---|---|---|---|
| | | ស្ត្រី | កុមារ | ចំនួនសម្រាល | |
| ១ | បន្ទាយមានជ័យ | ៦៨៧ | ៨៤ | ១៣២ | ៤៥៥ ១៦០ ០០០ |
| ២ | បាត់ដំបង | ១ ៩៧១ | ១៣៥ | ៣២៧ | ១ ២៩៩ ៤០០ ០០០ |
| ៣ | កំពង់ចាម | ៦៤១ | ៤៩ | ១៥៣ | ៤៣៧ ០០០ ០០០ |
| ៤ | កំពង់ឆ្នាំង | ៤២៥ | ៣០ | ១១៣ | ២៧៦ ៨០០ ០០០ |
| ៥ | កំពង់ស្ពឺ | ១៩៣ | ២៣ | ១២០ | ១៤១ ២៤០ ០០០ |
| ៦ | កំពង់ធំ | ៧៤៥ | ៧៥ | ១៣១ | ៤១៧ ៥២០ ០០០ |
| ៧ | កំពត | ៤០៣ | ២៤ | ៨១ | ២៩១ ០៨០ ០០០ |
| ៨ | កណ្ដាល | ៤៨៥ | ៤៣ | ១៤១ | ៣២៦ ៥២០ ០០០ |
| ៩ | កោះកុង | ១៦០ | ២២ | ២៩ | ៨០ ៥២០ ០០០ |
| ១០ | ក្រចេះ | ៧៥៤ | ៧២ | ២២៣ | ៤៧៤ ០០០ ០០០ |
| ១១ | មណ្ឌលគិរី | ១០៧ | ១៨ | ៣៨ | ៦២ ១២០ ០០០ |
| ១២ | ភ្នំពេញ | ៤៦៧ | ៨៧ | ៣១៦ | ៣៩៧ ៩៦០ ០០០ |
| ១៣ | ព្រះវិហារ | ៤១៥ | ២២ | ៨៦ | ២៩១ ២៤០ ០០០ |
| ១៤ | ព្រៃវែង | ៥៤៣ | ៩០ | ១៨៨ | ៤២៣ ៩២០ ០០០ |
| ១៥ | ពោធិ៍សាត់ | ៤៩៩ | ៤០ | ៩០ | ៣១០ ២៨០ ០០០ |
| ១៦ | រតនគិរី | ២៤៥ | ២៨ | ៥២ | ១៧២ ០៤០ ០០០ |
| ១៧ | សៀមរាប | ១ ១៤១ | ៩៤ | ១០៧ | ៦០៨ ៧៦០ ០០០ |
| ១៨ | ព្រះសីហនុ | ១០២ | ១៥ | ៦៧ | ៩៥ ៨៤០ ០០០ |
| ១៩ | ស្ទឹងត្រែង | ២២០ | ២០ | ៣៨ | ១៤៥ ៨៨០ ០០០ |
| ២០ | ស្វាយរៀង | ២១០ | ៣៥ | ៧៦ | ១៤៩ ៨០០ ០០០ |
| ២១ | តាកែវ | ៤៥២ | ៣២ | ១៥១ | ៣២៩ ៦៨០ ០០០ |
| ២២ | ឧត្ដរមានជ័យ | ៣២៨ | ៣០ | ៧៩ | ១៩៦ ៩៦០ ០០០ |

| | | | | | |
|---|---|---|---|---|---|
| ២៣ | កែប | ២៧ | ២ | ៧ | ១៧ ៧២០ ០០០ |
| ២៤ | ប៉ៃលិន | ១៤២ | ១១ | ៤១ | ៩៩ ០៤០ ០០០ |
| ២៥ | ត្បូងឃ្មុំ | ៦៥១ | ៥៨ | ១៣៩ | ៤០៩ ៨០០ ០០០ |
| **សរុប** | | **១២ ០១៣** | **១ ០៩៩** | **២ ៩២៥** | **៧ ៩១០ ២៨០ ០០០** |

-ក្នុងត្រីមាសទី១ ឆ្នាំ២០២២នេះ រាជរដ្ឋាភិបាលបានផ្តល់ការអន្តរាគមន៍ក្នុងការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ចំនួន ៦៨៦ ៩៩២គ្រួសារ ចំណាយថវិកាសរុបអស់ ១២១ ៣៥៩ ៦០០ ០០០៛។ បើគិតចាប់ថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២២ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់ការអន្តរាគមន៍ក្នុងការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ចំណាយថវិកាសរុបចំនួន ២ ៤៩១ ៦៧១ ០៣០ ០០០៛។

**១.១.៤.ការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងការធ្វើសមាហរណកម្មជនរងគ្រោះ**

-បានទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងធ្វើអាជីវកម្មផ្លូវភេទ រំលោភបំពានផ្លូវភេទដែលត្រូវបានធ្វើមាតុភូមិវត្តន៍ និងទទួលពីប្រទេសនានាសរុបចំនួន ៩៨នាក់ ស្រី៧៨នាក់ ក្នុងនោះ មកពីប្រទេសចិន ៦២នាក់ ម៉ាឡេស៊ី ២៤នាក់ នីហ្សេរីយ៉ា ០១នាក់ វៀតណាម ០៧នាក់ និងប្រទេសថៃ ០៤នាក់ និងបានធ្វើសមាហរណកម្មត្រឡប់ទៅសហគមន៍វិញចំនួន ៣២នាក់ ស្រី១៨នាក់

-បានទទួលជនរងគ្រោះដែលនិរទេសពីប្រទេសថៃ ៤៥ ៤០៣នាក់ ស្រី ២១ ១៨៥នាក់ និងបានធ្វើការសម្ភាសន៍ដើម្បីកំណត់អត្តសញ្ញាណរកមុខសញ្ញាជនរងគ្រោះ និងងាយរងគ្រោះ និងបញ្ជូនទៅទទួលសេវាបន្តនៅអង្គការដៃគូ

-ជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្សបានបញ្ជូនទៅស្តារនីតិសម្បទានៅមជ្ឈមណ្ឌលអង្គការដៃគូចំនួន ៨៣៦នាក់។

**អនុកម្មវិធីទី១.២.ការអភិវឌ្ឍសុខុមាលភាពកុមារ និងយុវនីតិសម្បទា**

**១.២.១.ការងារមជ្ឈមណ្ឌលកុមារកំព្រា និងការថែទាំកុមារ**

-ក្នុងត្រីមាសទី១ ឆ្នាំ២០២២នេះ មណ្ឌលថែទាំកុមារមានចំនួន១៩៩មណ្ឌល មានកុមារសរុបចំនួន ៥ ៤៤០នាក់ កុមារីចំនួន ២ ៥៦៩នាក់ និងយុវជនវ័យក្មេង (អាយុ១៨ឆ្នាំឡើង) ចំនួន ១ ៧១៦នាក់ ស្រី៨៨៧នាក់ ក្នុងនោះមណ្ឌលថែទាំដែលគ្រប់គ្រងនិងគាំទ្រដោយអង្គការមិនមែនរដ្ឋាភិបាល មានចំនួន ១៧៨មណ្ឌល មានកុមារចំនួន ៤ ៧៣៤នាក់ កុមារីចំនួន ២ ២៧៩នាក់ និងយុវជនវ័យក្មេង (អាយុ១៨ឆ្នាំឡើង) ចំនួន ១ ៣៩០នាក់ ស្រីចំនួន ៧២២នាក់ មណ្ឌលថែទាំរបស់រដ្ឋមានចំនួន២១ មានកុមារចំនួន ៧០៨នាក់ កុមារីចំនួន ២៩០នាក់ និងយុវជនវ័យក្មេង (អាយុ១៨ឆ្នាំឡើង) ចំនួន ៣២៦នាក់ ស្រី ១៦៥នាក់។ កន្លែងថែទាំបែបសហគមន៍មានចំនួន ១០១កន្លែង មានកុមារចំនួន ២ ១៨៦នាក់ កុមារីចំនួន ១ ០៤៧នាក់ និងយុវជនវ័យក្មេង (អាយុ១៨ឆ្នាំឡើង) ចំនួន៥២១នាក់ ស្រីចំនួន ២៧២នាក់។ មណ្ឌលកុមារកំព្រាមួយចំនួនទទួលការឧបត្ថម្ភបន្ថែមពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ក្នុងនោះ៖

តារាងទី៣៖ ការឧបត្ថម្ភរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជូនមណ្ឌលកុមារកំព្រា

| **លរ** | **ឈ្មោះមណ្ឌល/អង្គការ** | **ការឧបត្ថម្ភ** | | |
|---|---|---|---|---|
| | | **អង្ករ** | **ថវិកា** | **សម្ភារ** |
| ១ | បុរីទារក និងកុមារជាតិ | ២តោន/ឆ្នាំ | ១០លានរៀល/ឆ្នាំ | គ្រឿងបរិភោគ/ឆ្នាំ |
| ២ | មណ្ឌលសាលាគថ្លង់ភ្នំពេញថ្មី | ១តោន/ខែ | ៣លានរៀល/ខែ | |
| ៣ | មណ្ឌលសាលាគថ្លង់ច្បារអំពៅ | ១តោន/ខែ | ៣លានរៀល/ខែ | |
| ៤ | មណ្ឌលកុមារកំព្រាភ្នំពេញថ្មី | ៥០០គីឡូក្រាម/ខែ | ១លានរៀល/ខែ | |
| ៥ | មជ្ឈមណ្ឌលកុលាបទី៤ | | ៣លានរៀល/ខែ | |
| ៦ | មណ្ឌលផ្កាម្លិះ | ១តោន/ខែ | ៣លានរៀល/ខែ | |
| ៧ | សមាគមជនគ្មានទីពឹង | ១តោន/ខែ | ៣លានរៀល/ខែ | |
| ៨ | បុរីកុមារមិត្តភាពកម្ពុជាបារាំងហុងគ្រី | | ១,៩លានរៀល/ខែ | |

-បុរីទារក និងកុមារជាតិបាននិងកំពុងទទួលកុមារឱ្យស្នាក់នៅសរុបចំនួន ១៤៤នាក់ ស្រី ៦៨នាក់ ក្នុងនោះ កុមារពិការ ១២៨នាក់ កុមារផ្ទុកមេរោគអេដស៍ ០៧នាក់ និងកុមារធម្មតា ០៩នាក់។ ក្រៅពីអំណោយដ៏ថ្លៃថ្លារបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត** បុរីទារកនិងកុមារជាតិ តែងតែទទួលការឧបត្ថម្ភពីឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ហោ ណាំហុង** ចំនួន ៥ ០០០ដុល្លារអាមេរិក ជារៀងរាល់ខែ

-បានសហការជាមួយអង្គការភូមិកុមារ SOS រៀបចំពិធីសម្ពោធភូមិកុមារ SOS នៅភូមិលេខ១ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

**១.២.២.ការងារថែទាំជំនួសចំពោះកុមារ និងអធិការកិច្ច**

-បានសហការជាមួយក្រសួងមហាផ្ទៃ រៀបចំវគ្គបណ្តុះបណ្តាលស្តីពីការណែនាំការអនុវត្តគម្រោងកិច្ចការពារកុមារ និងការគ្រប់គ្រងថវិកា ជូនដល់ក្រុមការងារកិច្ចការពារកុមារ និងមន្ត្រីពិនិត្យបញ្ជាក់នៃគម្រោងលើកកម្ពស់វិស័យសេវាសង្គម នៅខេត្តព្រៃវែង ដែលមានអ្នកចូលរួម ៧០នាក់ មកពីខេត្តក្រចេះ រតនៈគីរី និងព្រៃវែង

-បានសហការជាមួយក្រសួងមហាផ្ទៃ រៀបចំកិច្ចប្រជុំតាមអនឡាញ ដើម្បីពិនិត្យ និងកែសម្រួលសេចក្តីព្រាងផែនការយុទ្ធសាស្ត្រវិស័យកិច្ចការពារកុមារ

-បានរៀបចំសេចក្តីព្រាងទម្រង់បែបបទសម្រាប់អនុវត្តប្រកាស ស្តីពីនីតិវិធីអនុវត្តការថែទាំកុមារដោយសាច់ញាតិ និងឪពុកម្តាយធម៌ និងបានផ្សព្វផ្សាយប្រកាស ស្តីពីនីតិវិធីអនុវត្តការថែទាំដោយសាច់ញាតិ និងឪពុកម្តាយធម៌ដល់មន្ត្រីបង្គោល និងបុគ្គលិកសង្គមកិច្ចនៃមន្ទីរ ស.អ.យ. និងអង្គការដៃគូ តាមប្រព័ន្ធអនឡាញ ដែលមានអ្នកចូលរួម ១៥០នាក់

-បានសហការជាមួយក្រសួងកិច្ចការនារី រៀបចំ និងសម្របសម្រួលវគ្គបណ្តុះបណ្តាលស្តីអំពី យេនឌ័រ និងកិច្ចការពារកុមារ សម្រាប់មន្ត្រីជួរមុខសហគមន៍ចំនួន៦ខេត្តគឺ ខេត្តបាត់ដំបង បន្ទាយមានជ័យ ឧត្តរមានជ័យ ប៉ៃលិន សៀមរាប និងខេត្តកំពង់ចាម ដែលមានអ្នកចូលរួមចំនួន ៤៩៦នាក់

-បានផ្តល់វិញ្ញាបនបត្រដល់មណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាលចំនួន ០៨មណ្ឌល។

**១.២.៣.ការងារសុំកូនអន្តរប្រទេស**

-បានបញ្ចូលក្នុងប្រព័ន្ធទិន្នន័យនូវសំណុំឯកសារចាស់ៗនៃការសុំកូនអន្តរប្រទេសចំនួន ៥១ករណី

-បានទទួលរបាយការណ៍ស្តីពីការវិវឌ្ឍរបស់កូនសុំ ០២ករណី មកពីប្រទេសអូទ្រីស ដែលតាមការបញ្ជាក់វាយតម្លៃ ពីស្ថានភាពកូនមានលក្ខណៈល្អប្រសើរទាំងផ្នែក សុខភាព ការរស់នៅ និងសិក្សារៀនសូត្រ។

**១.២.៤.ការងារក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ** (ក.ជ.ក)

បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីកិច្ចការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញចំនួន ៣វគ្គ ដល់មន្ត្រីនគរបាល (ស្នងការរងនិងប្រធានការិយាល័យប្រឆាំងបទល្មើសបច្ចេកវិទ្យា) អ្នកសារព័ត៌មានជាតិ និងចៅក្រមព្រះរាជអាជ្ញានិងមេធាវី ទាំង២៥ រាជធានី ខេត្ត ដែលមានអ្នកចូលរួម ២៨៨នាក់ ស្រី ១០៨នាក់។

**១.២.៥.ការងារយុវនីតិសម្បទា**

**១.២.៥.១.ការអប់រំ ទប់ស្កាត់កុមារ យុវជនប្រព្រឹត្តបទល្មើស និងសេពគ្រឿងញៀន**

-បានធ្វើបច្ចុប្បន្នភាពអនីតិជនទំនាស់នឹងច្បាប់នៅតាមពន្ធនាគារ និងមណ្ឌលអប់រំកែប្រែតាមរាជធានី ខេត្ត មានអនីតិជនសរុបចំនួន ១ ៣៣៦នាក់ ស្រី ៥៣នាក់

-បានចេញប្រកាសបញ្ចូលទណ្ឌិតជាអនីតិជនទំនាស់នឹងច្បាប់ចំនួន ៥០នាក់ ទៅស្នាក់នៅក្នុងមណ្ឌលយុវនីតិសម្បទា

-បានអនុវត្តកម្មវិធីបង្វែរអនីតិជនទំនាស់នឹងច្បាប់ ដោយក្នុងនោះ:

*ដំណាក់កាលរៀបចំរបាយការណ៍ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនទំនាស់នឹងចំនួន ៥០ករណី

*ដំណាក់កាលចូលរួមស្តាប់ចម្លើយក្នុងសវនាការចំនួន ៤៣ករណី

*និងដំណាក់កាលបើកការគ្រប់គ្រងករណីអនីតិជនទំនាស់នឹងច្បាប់ចំនួន ៤១ករណី

-បានរៀបចំវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រី ស្តីពីការអនុវត្តផែនការបង្វែរចំនួន ១វគ្គ ដែលមានអ្នកចូលរួម ៤៣នាក់ ស្រី១៦នាក់។

**១.២.៥.២.ការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន**

-បានសហការជាមួយអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន រៀបចំសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ មជ្ឈមណ្ឌលជាតិព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍នៅភូមិបឬទ្ធី២ ឃុំកែវផុស

ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម **កែវ គីមយ៉ាន** ឧបនាយករដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

-បានទទួលជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន ២ ៧៦៨នាក់ ស្រី ១៥៨នាក់ ឱ្យស្នាក់នៅ បន្សាបព្យាបាល និងស្តារនីតិសម្បទា និងបញ្ចេញជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន ២ ១៧៩នាក់ ស្រី ១៤០នាក់ នៅសល់ជាក់ស្តែងក្នុងត្រីមាសទី១ឆ្នាំ២០២២នេះ ចំនួន ៣ ៥៨៧នាក់ ស្រី ១៦៨នាក់។

តារាងទី៤ ៖ ចំនួនជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀននៅតាមមជ្ឈមណ្ឌល

| ល.រ | មជ្ឈមណ្ឌល | សល់ក្នុងឆ្នាំ២០២១ | | បញ្ចូលត្រីមាសទី១ឆ្នាំ ២០២២ | | បញ្ចេញត្រីមាសទី១ឆ្នាំ ២០២២ | | សល់ជាក់ស្តែងត្រីមាសទី១ឆ្នាំ២០២២ | |
|---|---|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | មជ្ឈមណ្ឌលជាតិព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនក្រាំងធ្នង់ ភ្នំពេញ | ២៤០ | ០៥ | ១០៤ | ០៣ | ៣៨ | ០០ | ៣០៦ | ០៨ |
| ២ | មជ្ឈមណ្ឌលជាតិផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសមាគមន៍ដល់អ្នកញៀនគ្រឿងញៀន ខេត្តព្រះសីហនុ | ៨៩ | ០០ | ៣៥ | ០០ | ២៥ | ០០ | ៩៩ | ០០ |
| ៣ | មណ្ឌលជីវិតថ្មីភ្នំបាក់ខេត្តបន្ទាយមានជ័យ | ៧២០ | ១៩ | ២៩៤ | ១៧ | ៣៦៤ | ០៤ | ៦៥០ | ៣២ |
| ៤ | មណ្ឌលឱកាសខ្ញុំរាជធានីភ្នំពេញ | ១ ៣៨៦ | ១១៤ | ១ ៨២៣ | ១២១ | ១ ២៤៥ | ១២៤ | ១ ៩៦៤ | ១១១ |
| ៥ | មណ្ឌលពិភពនៃក្តីសង្ឃឹមខេត្តបាត់ដំបង | ២៨៧ | ០៥ | ១០២ | ០០ | ១៥២ | ០៥ | ២៣៧ | ០០ |
| ៦ | មណ្ឌលកងរាជអាវុធហត្ថខេត្តបាត់ដំបង | ០០ | ០០ | ០០ | ០០ | ០០ | ០០ | ០០ | ០០ |
| ៧ | មណ្ឌលបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ | ០០ | ០០ | ០០ | ០០ | ០០ | ០០ | ០០ | ០០ |
| ៨ | មណ្ឌលស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនខេត្តសៀមរាប | ២៧៦ | ០៧ | ៤១០ | ១៧ | ៣៥៥ | ០៧ | ៣៣១ | ១៧ |
| ៩ | មណ្ឌលបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តព្រះសីហនុ | ០០ | ០០ | ០០ | ០០ | ០០ | ០០ | ០០ | ០០ |
| | សរុប | ២ ៩៩៨ | ១៥០ | ២ ៧៦៨ | ១៥៨ | ២ ១៧៩ | ១៤០ | ៣ ៥៨៧ | ១៦៨ |

**អនុកម្មវិធីទី១.៣.ការអភិវឌ្ឍសុខុមាលភាពជនពិការ**

-បានរៀបចំសិក្ខាសាលាស្តីពីការកំណត់អត្តសញ្ញាណកម្មពិការភាព តាមគំរូសង្គម និងសិទ្ធជាមូលដ្ឋាននៅភោជនីដ្ឋានទន្លេសាក់២ ដែលមានអ្នកចូលរួមចំនួន៩២នាក់

-បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយសេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការដើម្បីចូលរួមគាំទ្រ និងអនុវត្តការងាររៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី៣២ និងអាស៊ាប៉ារ៉ាហ្គេមលើកទី១២ នៅពហុកីឡាដ្ឋានជាតិមរតតេជោ

-បានរៀបចំវគ្គបណ្តុះបណ្តាលរំលឹកគ្រូបង្គោលថ្នាក់ជាតិ ស្តីពីហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលនៅសណ្ឋាគារភ្នំពេញរាជធានីភ្នំពេញ និងបានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលនៅខេត្តបាត់ដំបង

-បានរៀបចំវគ្គបណ្តុះបណ្តាលអំពីរបៀបប្រើប្រាស់ប្រព័ន្ធ App និង Web ព័ត៌មានពិការភាពនៅកម្ពុជា តាមហ្សូម

-បានរៀបចំសិក្ខាសាលាពង្រឹងសមត្ថភាពមន្ត្រីនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ នៅសណ្ឋាគារកាំបូឌីយ៉ាណា

-បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការប្រឹក្សាយោបល់ជាមូលដ្ឋានដល់ស្ត្រី និងកុមារីរងគ្រោះដោយសារអំពើហិង្សាយេនឌ័រ និងជំនាញមូលដ្ឋានក្នុងការប្រឹក្សាយោបល់ផ្លូវចិត្ត នៅសណ្ឋាគារកាំបូឌីយ៉ាណា

-បានប្រគល់រទេះរុញ ១២គ្រឿង ជូនជនពិការ

-បានបោះពុម្ព ប័ណ្ណសំគាល់ពិការភាព ចំនួន ៥ ៥០០កាត សម្រាប់ចែកជូនជនពិការ

-រហូតមកដល់ចុងខែមីនា ឆ្នាំ២០២២ ជនពិការចំនួន ២៣៨ ៩៤១នាក់ ស្រី ១១២ ៥៩៨នាក់ ត្រូវបានសម្ភាសដើម្បីកំណត់អត្តសញ្ញាណជនពិការតាមតាមបែបគំរូសង្គម និងសិទ្ធជាមូលដ្ឋាន នៅតាមឃុំ សង្កាត់

-បានចុះតាមដាន និងត្រួតពិនិត្យការកំណត់អត្តសញ្ញាណពិការភាពតាមបែបគំរូសង្គម និងសិទ្ធិជាមូលដ្ឋាននៅខេត្តកំពង់ចាម កំពង់ធំ សៀមរាប ឧត្តរមានជ័យ ត្បូងឃ្មុំ ក្រចេះ និងខេត្តស្ទឹងត្រែង

-មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គមពោធិ៍សែនជ័យបានបើកវគ្គទី២២ ឆ្នាំ២០២២ បណ្តុះបណ្តាលវិជ្ជាជីវៈជូនជនពិការចំនួន ៣៥នាក់ ស្រី ០៦នាក់ លើជំនាញចំនួន ០៣ ក្នុងនោះ ជំនាញកាត់ដេរសម្លៀកបំពាក់ អ៊ុតសក់ និងតុបតែង ០៧នាក់ ជំនាញ ជួសជុលវិទ្យុ ទូរទស្សន៍ និងបរិក្ខាអគ្គិសនី ១៣នាក់ និងជំនាញជួសជុលម៉ូតូ និងម៉ាស៊ីនធុនតូច ១៥នាក់

-បានចេញវិញ្ញាបនបត្របញ្ជាក់ការអនុវត្តច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការជូនរោងចក្រ សហគ្រាស ចំនួន ៥៣

-គិតមកដល់ចុងខែមករា ឆ្នាំ២០២២នេះ ក្រសួងបានចុះបញ្ជិកាជូនរោងចក្រ សហគ្រាសសរុបចំនួន ២៧៥អង្គភាព និង មានអង្គភាពចំនួន ១២ បានបង់ភាគទានជូនមូលនិធិជនពិការ។

**អនុកម្មវិធីទី១.៤.ការអភិវឌ្ឍសុខុមាលភាពមនុស្សចាស់**

-បានប្រជុំពិភាក្សាជាមួយទីប្រឹក្សារបស់ UNDP ស្តីពីពហុសោធនរបស់មនុស្សវ័យចាស់ និងបញ្ហាសន្តិសុខហិរញ្ញវត្ថុរបស់មនុស្សវ័យចាស់

-បានពិនិត្យ និងកែសម្រួលផែនការសកម្មភាពដំណាក់កាលទី២ (២០២១-២០២៥) នៃគោលនយោបាយជាតិ ស្តីពីមនុស្សវ័យចាស់ ២០១៧-២០៣០

-បានចុះសួរសុខទុក្ខមនុស្សវ័យចាស់ចំនួន ១០០គ្រួសារ នៅឃុំកណ្តោលជ្រុំ ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ

-បានពិនិត្យកែសម្រួលអនុក្រឹត្យលេខ ១៥៨អនក្រ.បក ស្តីពីការបង្កើតគណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់។

**អនុកម្មវិធីទី១.៥.ការអភិវឌ្ឍសុខុមាលភាពអតីតយុទ្ធជន**

-បានសហការជាមួយអង្គការក្រុមនៃក្តីមេត្តាអន្តរជាតិផ្តល់ជំនួយសប្បុរសធម៌ជូនដល់អតីតយុទ្ធជន និងគ្រួសារចំនួន ៤០០គ្រួសារ

-គិតមកដល់ចុងឆ្នាំ២០២១ សមាជិកសមាគមអតីតយុទ្ធជនកម្ពុជាសរុបចំនួន ៨០ ៦៩១នាក់

-បានទទួលសំណុំបែបបទស្នើសុំប្រាក់បេឡាមរណសង្គ្រោះពី ស.អ.ក. រាជធានី/ខេត្តចំនួន ៤៤៨សព។ គិតពីឆ្នាំ ២០០៨ មកដល់ត្រឹមថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២២ គណៈអចិន្ត្រៃយ៍ ស.អ.ក. បានទទួលសំណុំបែបបទស្នើសុំប្រាក់ ប.ម.ស. សរុបចំនួន ១៨ ៤៩២សព និងបានចេញសេចក្តីសម្រេចស្តីពីការប្រគល់ថវិកា ប.ម.ស. ជូនសមាជិក ស.អ.ក. ទាំងស្រុង។

***<u>កម្មវិធីទី២</u>.ការបង្កើនប្រសិទ្ធភាពប្រព័ន្ធសន្តិសុខសង្គម និងផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាជនពិការ***

**អនុកម្មវិធីទី២.១.ការបង្កើនប្រសិទ្ធភាពសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល**

-បានរៀបចំបែបបទទទួលស្គាល់មន្ត្រីរាជការឱ្យចូលនិវត្តន៍ និងឧបត្ថម្ភប្រាក់គោលនយោបាយរបបសន្តិសុខសង្គម ចំនួន ៥៤នាក់ និងអ្នកនៅក្នុងបន្ទុក ៤៣នាក់ ព្រមទាំងផ្ទេរការគ្រប់គ្រងទៅតាមរាជធានី ខេត្ត

-បានចេញប្រកាសលុបសពនិវត្តជន និងសពជនបាត់បង់សម្បទាវិជ្ជាជីវៈសរុបចំនួន ៨៥៨នាក់ និងបន្តឧបត្ថម្ភប្រាក់គោលនយោបាយរបបសន្តិសុខសង្គមជូនអ្នកនៅក្នុងបន្ទុកចំនួន ៥៤៨នាក់

-បានផ្តល់ប្រាក់របបសន្តិសុខសង្គមជូនសពមន្ត្រីរាជការស៊ីវិល ១៦នាក់ និងផ្ទេរកូនសពមន្ត្រីរាជការស៊ីវិល ០៧នាក់

-បានលុបឈ្មោះប្រពន្ធនៅក្នុងបន្ទុក ០៤នាក់ និងកូននៅក្នុងបន្ទុក ៧៤៦នាក់

-បានបើកប្រាក់នៅសល់ក្នុងគណនីជូនគ្រួសារសព និវត្តជននិងជនបាត់បង់សម្បទាវិជ្ជាជីវៈ ២៣៤នាក់

-បានបើកប្រាក់របបសន្តិសុខសង្គមជូនគ្រួសារសពនិវត្តជន និងគ្រួសារសពជនបាត់បង់សម្បទាវិជ្ជាជីវៈ ៧៨១នាក់

-បានបើកប្រាក់របបសន្តិសុខសង្គមជូនអ្នកនៅក្នុងបន្ទុកសពនិវត្តជន សពជនបាត់បង់សម្បទាវិជ្ជាជីវៈ និងបន្ទុករបស់សពមន្ត្រីរាជការស៊ីវិលចំនួន ១២ ០៧៥នាក់

-បានផ្ទេរសិទ្ធិជូនសិទ្ធិវន្តដែលមានជំងឺស្នើសុំផ្ទេរសិទ្ធិចំនួន ៣៤នាក់

តារាងទី៥៖ ទិន្នន័យធ្វើបច្ចុប្បន្នភាពសិទ្ធិវន្តរបស់ ប.ជ.ស. ក្នុងត្រីមាសទី១ ឆ្នាំ២០២២

| ល.រ | សិទ្ធិវន្ត | ចំនួន | អ្នកនៅក្នុងបន្ទុក | | | | |
|---|---|---|---|---|---|---|---|
| | | | ប្រពន្ធ | កូន | ប្រពន្ធសព | កូនសព | កូនសពមន្ត្រីរាជការស៊ីវិល |
| ១ | និវត្តជន | ៧៩៥ | ៣០៤ | ១៥៣ | ៤ | ២ | ៤ |
| ២ | ជនបាត់បង់សម្បទាវិជ្ជាជីវៈ | ០ | ០ | ០ | ០ | ០ | |
| ៣ | អ្នកនៅក្នុងបន្ទុក | ៤៦៧ | ៣០៤ | ១៥៣ | ៤ | ២ | ៤ |
| សរុបរួម | | ១ ២៦២ | | | | | |

(ប្រភព ប.ជ.ស.)

តារាងទី៦៖ ទិន្នន័យសរុបរបស់សិទ្ធិវន្តដែលធ្វើបច្ចុប្បន្នភាពគិតត្រឹមខែមីនា ឆ្នាំ២០២២

| ល.រ | សិទ្ធិវន្ត | ចំនួន | អ្នកនៅក្នុងបន្ទុក | | | | |
|---|---|---|---|---|---|---|---|
| | | | ប្រពន្ធ | កូន | ប្រពន្ធសព | កូនសព | កូនសពមន្ត្រីរាជការស៊ីវិល |
| ១ | និវត្តជន | ៥៥ ៨៣០ | ៣០ ២៣៩ | ២ ៧២០ | ៩ ២៨៣ | ២៤៩ | ១០៤ |
| ២ | ជនបាត់បង់សម្បទាវិជ្ជាជីវៈ | ១ ៧៥០ | ៧៤៤ | ១ | ១ ០១៣ | ៤ | |
| ៣ | អ្នកនៅក្នុងបន្ទុក | ៤៤ ៣៥៧ | ៣០ ៩៨៣ | ២ ៧២១ | ១០ ២៩៦ | ២៥៣ | ១០៤ |
| សរុបរួម | | ១០១ ៩៣៧ | | | | | |

(ប្រភព ប.ជ.ស.)

តារាងទី៧៖ ទិន្នន័យសិទ្ធិវន្តនៃ ប.ជ.ស. ដែលកំពុងបើករបបតាមប្រព័ន្ធធនាគារ ក្នុងខែមីនា ឆ្នាំ២០២២

| ល.រ | សិទ្ធិវន្ត | ចំនួន | អ្នកនៅក្នុងបន្ទុក | |
|---|---|---|---|---|
| | | | ប្រពន្ធ | កូន |
| ១ | និវត្តជន | ៥៤ ៣៣២ | ២៩ ៣១១ | ៣ ៥៣២ |
| ២ | ជនបាត់បង់សម្បទាវិជ្ជាជីវៈ | ១ ៦១២ | ៦៩៨ | ៤ |
| ៣ | អ្នកនៅក្នុងបន្ទុក | ៣៣ ៥៤៥ | ៣០ ០០៩ | ៣ ៥៣៦ |
| សរុបរួម | | ៨៩ ៤៨៩ | (ប្រភព ប.ជ.ស.) | |

**អនុកម្មវិធីទី២.២.ការបង្កើនប្រសិទ្ធភាពសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន និងគ្រួសារ**

-ទទួលអតីតយុទ្ធជនដែលផ្ទេរពីក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃសរុបចំនួន ៥៧៦នាក់

-បញ្ចូលបន្ទុកអតីតយុទ្ធជន ២១នាក់ និងលុបបន្ទុកអតីតយុទ្ធជន ៤៤៥នាក់

-ផ្ទេរអតីតយុទ្ធជនតាមមន្ទីរ ស.អ.យ. រាជធានី ខេត្ត ៤៨នាក់ និងទទួលស្គាល់របបឧបត្ថម្ភឡើងវិញ ០១នាក់

-ផ្តល់ប្រាក់បូជាសព មួយលើកដំបូង និងប្រាក់ធានារ៉ាប់រងសង្គម ៣៨៣នាក់

-ផ្តល់ប្រាក់វិលទៅមូលដ្ឋានជូនជនពិការ ១៩២នាក់

តារាងទី៨៖ កំណត់ប្រាក់របបសន្តិសុខសង្គមជូនអតីតយុទ្ធជន និងគ្រួសារក្នុងត្រីមាសទី១ ឆ្នាំ២០២២

| ល.រ | មុខសញ្ញា | ចំនួន | បន្ទុកដែលត្រូវទទួលរបប | | | | | | | ទឹកប្រាក់សរុប |
|---|---|---|---|---|---|---|---|---|---|---|
| | | | ឪពុក | ម្តាយ | អា.ព្យា | ប្រពន្ធ | កូន | អ្នកបម្រើ | សរុប | |
| ១ | ជនពលី | | | | | | | | | |
| ២ | ជនមរណៈ | ៥៩ | ១៥ | ៣០ | | ៥៣ | ៥៨ | | ១៥៦ | ១ ៧៣៥ ០០០៛ |
| ៣ | ជនពិការ | ១ ៣៣៥ | | | | ១ ០៣២ | ៦៨៦ | ២២៤ | ១ ៩៤២ | ១ ៦២២ ៣៦១ ២០០៛ |
| ៤ | និវត្តជន | ១ ៧៤៩ | | | | ១ ៤៩៧ | ១ ១១០ | | ២ ៦០៧ | ២ ១៦១ ៦៣៧ ១៣៤៛ |
| ៥ | ជនបាត់បង់ | | | | | | | | | |
| សរុប | | ៣ ១៤៣ | ១៥ | ៣០ | | ២ ៥៨២ | ១ ៨៥៤ | ២២៤ | ៤ ៧០៥ | ៣ ៧៨៥ ៧៣៣ ៣៣៤៛ |

(ប្រភព ប.ជ.អ.)

តារាងទី៩៖ លុបឈ្មោះអតីតយុទ្ធជនដែលទទួលមរណភាព និងទទួលស្គាល់ជាជនពលី និងមរណៈវិញ

| ល.រ | មុខសញ្ញា | ចំនួន | បន្ទុកដែលទទួលប្រាក់ឧបត្ថម្ភ | | | | | | | ទឹកប្រាក់សរុប |
|---|---|---|---|---|---|---|---|---|---|---|
| | | | ឪពុក | ម្តាយ | អា.ព្យា | ប្រពន្ធ | កូន | អ្នកបម្រើ | សរុប | |
| ១ | ជនពិការ | ១២០ | | | | ១០៦ | ៤៦ | | ១៥២ | ១១០ ៧៣៦ ០២៣៛ |
| ២ | និវត្តជន | ១៧១ | | ៣ | | ១៥៤ | ២៨ | | ១៨៥ | ១៥៩ ៩៣៤ ៥០៥៛ |
| ៣ | ជនបាត់បង់ | ៣ | | ១ | | ២ | | | ៣ | ១ ៩២០ ០០០៛ |
| សរុប | | ២៩៤ | | ៤ | | ២៦២ | ៧៤ | | ៣៤០ | ២៧២ ៥៩០ ៥២៨៛ |

(ប្រភព ប.ជ.អ.)

តារាងទី១០៖ លុបឈ្មោះអតីតយុទ្ធជន និងគ្រួសារចេញពីបញ្ជីបើកប្រាក់ក្នុងត្រីមាសទី១ ឆ្នាំ២០២២

| ល.រ | មុខសញ្ញា | ចំនួន | បន្ទុកដែលត្រូវកាត់ចេញ | | | | | | | ទឹកប្រាក់សរុប |
|---|---|---|---|---|---|---|---|---|---|---|
| | | | ឪពុក | ម្តាយ | អា.ព្យា | ប្រពន្ធ | កូន | អ្នកបម្រើ | សរុប | |
| ១ | ជនពលី | ៩២ | ២៥ | ៣៥ | ១ | ៣១ | ២២ | | ១១៤ | ១ ១៧៣ ០០០៛ |
| ២ | ជនមរណៈ | ១៤ | ១ | ២ | ១ | ៦ | ៤ | | ១៤ | ១៦២ ០០០៛ |
| ៣ | ជនពិការ | | | | | | | | | |
| ៤ | និវត្តជន | | | | | | | | | |
| ៥ | ជនបាត់បង់ | | | | | | | | | |
| សរុប | | ១០៦ | ២៦ | ៣៧ | ២ | ៣៧ | ២៦ | | ១២៨ | ១ ៣៣៥ ០០០៛ |

(ប្រភព ប.ជ.អ.)

តារាងទី១១៖ អតីតយុទ្ធជន និងគ្រួសារដែលកំពុងទទួលប្រាក់របបសន្តិសុខសង្គមក្នុងខែមីនា ឆ្នាំ២០២២

| ល.រ | មុខសញ្ញា | ចំនួន | បន្ទុកដែលត្រូវទទួលរបប | | | | | | | ទឹកប្រាក់សរុប |
|---|---|---|---|---|---|---|---|---|---|---|
| | | | ឪពុក | ម្តាយ | អា.ព្យា | ប្រពន្ធ | កូន | អ្នកបម្រើ | សរុប | |
| ១ | ជនពលី | ២៦ ៨៦០ | ៥ ៥៨០ | ១០ ៨៣៦ | ១៧៧ | ២០ ៥៣២ | ៧ ២៣៦ | | ៤៤ ៣៦១ | ៥១៣ ១៥៧ ០០០៛ |
| ២ | ជនមរណៈ | ៩ ៦៩៧ | ១ ២១៧ | ២ ២៨១ | ៣៥ | ៨ ៩៦៤ | ៤ ៦១២ | | ១៧ ១០៩ | ២០៨ ៩២៤ ០០០៛ |
| ៣ | ជនពិការ | ២៩ ៩៦៦ | | | | ២៥ ១១៧ | ១៣ ១៨២ | ១ ៨៤៦ | ៤០ ១៤៥ | ២៣ ៥៦៩ ៥៤៣ ៣៣៩៛ |
| ៤ | និវត្តជន | ៣៧ ៥៩០ | | | | ៣១ ៧៣៧ | ១៦ ៥០៥ | | ៤៨ ២៤២ | ៣២ ៩៥៩ ៦៧១ ៥៥៤៛ |
| ៥ | ជនបាត់បង់ | ១ ៤៦៩ | | | | ១ ០៩៦ | ៤៨៨ | ៦៨ | ១ ៦៥២ | ៩៤៥ ៦៣៧ ៦៩៨៛ |
| សរុប | | ១០៥ ៥៨២ | ៦ ៧៩៧ | ១៣ ១១៧ | ២១២ | ៨៧ ៤៤៦ | ៤២ ០២៣ | ១ ៩១៤ | ១៥១ ៥០៩ | ៥៨ ១៩៦ ៩៣៣ ៥៩១៛ |

(ប្រភព ប.ជ.អ.)

## អនុកម្មវិធីទី២.៣.ការបន្តនិរន្តរភាពការផ្តល់សេវាស្តារលទ្ធភាពពលកម្មជូនជនពិការ

-បានទទួលប្រាក់ភាគទានពីក្រសួង ស្ថាប័ន និងនីតិបុគ្គលដែលមិនបានជ្រើសរើសជនពិការចូលបម្រើការងារចំនួន ១៣៦ ៤៧៩ ០០០៛

-បានទទួលចំណូលពីការលក់ឧបករណ៍សិប្បនិម្មិត រណប និងឧបករណ៍ជំនួយរាងកាយចំនួន ១៩៩ ៩៦៦ ៧០០៛

-បានដាក់ហិបមូលនិធិជនពិការនៅតាមរាជធានី/ខេត្ត និងប្រមូលបានថវិកាសរុបចំនួន ១៥ ៥០៥ ១០០៛

-មូលនិធិជនពិការតាមរយៈមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា និងអង្គការដៃគូបានផ្តល់សេវាស្តារលទ្ធភាពពលកម្មគ្រប់ប្រភេទជូនជនពិការ ១៧ ៩៩៥នាក់ ក្នុងនោះសេវាស្តារលទ្ធភាពពលកម្មកាយសម្បទា ៧ ២៥៤នាក់ និងស្តារវេជ្ជសាស្ត្រ ១០ ៧៤១នាក់

-បានប្រគល់ផ្ទះ ០៣ខ្នង ជូនជនពិការនៅរាជធានីភ្នំពេញ ខេត្តកំពង់ឆ្នាំង និងខេត្តព្រៃវែង។

### ២.៣.១.ការផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទា

-ដោយមានការសហការ ជួយឧបត្ថម្ភរបស់អង្គការមិនមែនរដ្ឋាភិបាល ដែលមានកិច្ចសហការជាមួយក្រសួង ស.អ.យ. មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា និងរោងជាងសរុបចំនួន ១៥កន្លែង បានផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាគ្រប់ប្រភេទជូនជនពិការសរុបចំនួន ៧ ២៥៤នាក់ ស្រី ១ ៨០៤នាក់ និងជនពិការដោយសារមីន ៣ ០០១នាក់។ ទន្ទឹមនេះ ជនពិការដែលមកទទួលសេវាពីមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មដោយឥតគិតថ្លៃ ព្រមទាំងបានទទួលការឧបត្ថម្ភជាប្រាក់អាហារ និងថ្លៃធ្វើដំណើរទៅមកផងដែរ

-បានផ្តល់អវយវៈសិប្បនិម្មិត រណប និងឧបករណ៍ជំនួយការរាងកាយសរុបចំនួន ៣ ៦៥២គ្រឿង/រាយ

-បានជួសជុលអវយវៈសិប្បនិម្មិត រណប និងឧបករណ៍ជំនួយរាងកាយសរុបចំនួន ៣ ៨៥៥គ្រឿង/រាយ

-បានព្យាបាលដោយចលនាចំនួន ៨៩៨នាក់ ស្មើនឹងចំនួនព្យាបាល ១៧ ៧២៨ដង

-ផ្តល់ការស្នាក់នៅជូនជនពិការអំឡុងពេលទទួលសេវាបាន ១ ៦១៤នាក់ និងអ្នកកំដរ ២៣៣នាក់។

### ២.៣.២.ការផ្តល់សេវាស្តារលទ្ធភាពពលកម្មវេជ្ជសាស្ត្រ

បានពិនិត្យ និងព្យាបាល វះកាត់ភ្នែក ដាក់កែវភ្នែកសិប្បនិម្មិត ដាក់កញ្ចក់ក្នុងកែវភ្នែក ផ្តល់វ៉ែនតា វះកាត់ដៃជើងនិងមុខមាត់ ព្យាបាលជំងឺហង់សិន និងព្យាបាលអ្នកជំងឺរបួសខួរឆ្អឹងខ្នងបានចំនួនសរុប ១០ ៧៤១នាក់ ស្រី ៥ ៧០៥នាក់។

### ២.៣.៣.ការផ្តល់សេវាស្តារលទ្ធភាពពលកម្មនៅតាមសហគមន៍

-ជនពិការបានទទួលសេវាជួសជុលចល័តចំនួន ១ ៦៣២នាក់

-បានផ្តល់ រទេះរុញ ១០២គ្រឿង ឈើច្រត់ ២៩៥គ្រឿង និងស្បែកជើងខ្ពស់ទាប ៣៦គូ

-បានបញ្ជូនកុមារពិការទៅអង្គការគ្រួសារថ្មី ១០១នាក់

-បានបញ្ជូនកុមារពិការទៅសាលារៀន ១៧នាក់

-បានបញ្ជូនជនពិការទៅមណ្ឌល ០៥នាក់

-បានជួយរកការងារឱ្យជនពិការធ្វើ ១២នាក់

-បានផ្តល់កង់ជូនជនពិការ ១២នាក់

-បានចុះសួរសុខទុក្ខអ្នកជំងឺនៅក្នុងសហគមន៍ ១២១នាក់។

## កម្មវិធីទី៣.ការពង្រឹងសមត្ថភាពស្ថាប័ននិងអភិវឌ្ឍភាពជាដៃគូ

### អនុកម្មវិធីទី៣.១.ការពង្រឹងសមត្ថភាពស្ថាប័ន និងភាពជាដៃគូ

**៣.១.១.ការងាររដ្ឋបាល និងបុគ្គលិក**

-បានរក្សាទុក និងតម្កល់លិខិតបទដ្ឋានគតិយុត្ត មានសណ្តាប់ធ្នាប់ របៀបរៀបរយ ត្រឹមត្រូវ និងលាក់ការណ៍សម្ងាត់

-ក្របខ័ណ្ឌមន្ត្រីរាជការសរុបចំនួន ១ ៨០៦នាក់ ស្រី ៧០៦នាក់ (ថ្នាក់ជាតិ ៩៦៤នាក់ និងក្រោមជាតិ ៨៤៣នាក់)

-តែងតាំង និងប្រគល់ភារកិច្ច ០៥នាក់ និងដាក់មន្ត្រីរាជការឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស ០១នាក់

-អនុញ្ញាតឱ្យមន្ត្រីរាជការចូលបម្រើការងារវិញបន្ទាប់ពីទំនេរគ្មានបៀវត្ស ០១នាក់

-ផ្ទេរផ្ទៃក្នុងក្រសួង ០៣នាក់ ផ្ទេរចូល ០៣នាក់ និងផ្ទេរក្របខ័ណ្ឌចេញពីក្រសួង ០៣នាក់

-ការរៀបប្រាក់បៀវត្សជូនថ្នាក់ដឹកនាំ និងមន្ត្រីដែលតែងតាំង ២៥នាក់

-សម្រាកលំហែមាតុភាព ០៧នាក់

-ផ្តល់ប្រាក់ឧបត្ថម្ភអ្នកនៅក្នុងបន្ទុកមន្ត្រីរាជការ ២០នាក់ និងផ្តាច់ប្រាក់ឧបត្ថម្ភអ្នកនៅក្នុងបន្ទុក ១០នាក់

-បានបញ្ជូនមន្ត្រីទៅចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា ក្នុងប្រទេស ០៦នាក់។

**៣.១.២.ការងារផែនការ ស្ថិតិ និងសរុប**

-បានរៀបចំរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំខែមករា និងកុម្ភៈ ឆ្នាំ២០២២

-បានពិនិត្យ និងកែសម្រួលសេចក្តីព្រាងផែនការសកម្មភាពឆ្នាំ២០២២

-ក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការក្រសួងបានរៀបចំសេចក្តីព្រាង ស្តីពីនីតិវិធីអនុវត្តមុខងារពាក់ព័ន្ធនឹងក្រសួងសម្រាប់ការិយាល័យសង្គមកិច្ចនិងសុខុមាលភាពសង្គមនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

**៣.១.៣.ការងារគ្រប់គ្រងថវិកា និងសម្ភារ**

-បានបើកប្រាក់បៀវត្សប្រចាំខែ ជូនមន្ត្រីរាជការ បានទាន់ពេលវេលា

-បានផ្គត់ផ្គង់សម្ភារ បរិក្ខារ សង្ហារឹម ការជួសជុល និងប្រេងឥន្ធនៈ ជូនថ្នាក់ដឹកនាំ និងអង្គភាពក្រោមឱវាទ។

**៣.១.៤.ការងារសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាន**

-បានចុះត្រួតពិនិត្យសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ០៩ និងចុះកិច្ចព្រមព្រៀងជាមួយអង្គការចំនួន ១៨

-បានធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះអង្គការដែលចុះកិច្ចព្រមព្រៀងនៅមានសុពលភាពជាមួយក្រសួងចំនួន ១៤៣នាក់ ដែលមានថវិកាសរុបចំនួន ៣៣០ ១៩៣ ៤០៩,៥២ដុល្លារអាម៉េរិក

-បានសម្របសម្រួលផ្តល់លិខិតគាំទ្រសម្រាប់អង្គការស្នើសុំបន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិជូនអង្គការ ០៨ករណី

-បានចេញលិខិតគាំទ្រនាំចូលសម្ភារ និងនាំចូលយានយន្តដោយពន្ធ និងអាករជាបន្ទុករបស់រដ្ឋចំនួន ០៣នាក់

-បានចេញលិខិតគាំទ្រពន្យាទិដ្ឋាការជូនបុគ្គលិកសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ០៥នាក់

-បានចេញលិខិតគាំទ្រស្នើសុំស្លាកលេខប្រភេទអង្គការចំនួន ០៥ករណី

-បានចូលរួមរៀបចំពិធីសម្ពោធដាក់ឱ្យប្រើប្រាស់នូវសៀវភៅរបាយការណ៍របស់គណៈកម្មាធិការអាស៊ានស្តីពីការលើកកម្ពស់ និងការការពារសិទ្ធិស្ត្រី និងកុមារ ACWC ស្តីពីអត្តសញ្ញាណស្របច្បាប់សម្រាប់ស្ត្រី និងកុមារក្នុងតំបន់អាស៊ាន។

**៣.១.៥.ការងារសវនកម្មផ្ទៃក្នុង**

បានចុះធ្វើសវនកម្មនៅខេត្តបន្ទាយមានជ័យ បាត់ដំបង និងរាជធានីភ្នំពេញ ដើម្បីកែលម្អការគ្រប់គ្រងចំណាយថវិការដ្ឋ និងទ្រព្យសម្បត្តិរដ្ឋ នៅតាមមន្ទីរ ស.អ.យ. រាជធានី ខេត្ត សំដៅលើកកម្ពស់គណនេយ្យភាព តម្លាភាព ប្រសិទ្ធភាពនៃការផ្តល់សេវាសង្គមកិច្ចគ្រប់ប្រភេទ។

**៣.១.៦. ការងារអធិការកិច្ច**

-សម្រាប់ត្រីមាសទី១ ឆ្នាំ២០២២នេះ ក្រសួងមិនមានវិវាទការងារ ឬពាក្យបណ្តឹង សម្រាប់ដោះស្រាយឡើយ។

### អនុកម្មវិធីទី៣.២.ការអភិវឌ្ឍធនធានមនុស្ស

-សម្រាប់ឆ្នាំសិក្សា ២០២០-២០២១ វិទ្យាស្ថានជាតិសង្គមកិច្ចមាននិស្សិត ៤៤១នាក់ ស្រី ២៥៨នាក់ កំពុងបន្តការសិក្សា។

II-**ទិសដៅអនុវត្តបន្ត**

**កម្មវិធីទី១.ការបង្កើនប្រសិទ្ធភាពសេវាសុខុមាលភាពសង្គម**

**អនុកម្មវិធីទី១.១.ការអភិវឌ្ឍសុខុមាលភាពសម្រាប់ជនរងគ្រោះនិងងាយរងគ្រោះ និងកិច្ចការគ្រួសារ**

- បន្តរៀបចំកម្មវិធីជំនួយសង្គមជាកញ្ចប់គ្រួសារ តាមរយៈ ការធ្វើសមាហរណកម្មកម្មវិធីជំនួយសង្គមបញ្ចូលគ្នា រួមមាន កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះនិងកុមារអាយុក្រោម ២ឆ្នាំ កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនពិការ កម្មវិធីឧបត្ថម្ភមនុស្សវ័យចាស់ និងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនសិស្សក្រីក្រនៅតាមភូមិសិក្សា និងបន្តរៀបចំប្រព័ន្ធគ្រប់គ្រង និងការឆ្លើយតបគ្រោះអាសន្នក្នុងការផ្តល់ជំនួយសង្គម
- សិក្សា និងរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យជនចំណាកស្រុក សំដៅផ្តល់សេវាឆ្លើយតបបន្ទាន់សម្រាប់ជនចំណាកស្រុក និងបង្កាទប់ស្កាត់ជនអនាថា
- ដោះស្រាយបញ្ហាជនអនាថាតាមរយៈការផ្តល់សេវាអប់រំផ្លូវចិត្ត ពិគ្រោះយោបល់ ការថែទាំសុខភាព ស្តារនីតិសម្បទា បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ
- ទប់ស្កាត់ការធ្វើចំណាកស្រុកខុសច្បាប់ តាមរយៈ ការផ្សព្វផ្សាយអប់រំ ការបញ្ជ្រាបការយល់ដឹងស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព
- ការពង្រឹងប្រសិទ្ធភាពគ្រប់គ្រងមជ្ឈមណ្ឌលសំចតសង្គមកិច្ច និងការទទួលជនវិបល្លាសស្មារតីឱ្យស្នាក់នៅក្នុងមជ្ឈមណ្ឌលព្យាបាលនិងថែទាំជនវិបល្លាសស្មារតី
- ផ្តល់សេវាថែទាំគាំទ្រ និងសង្គ្រោះជនរងគ្រោះ និងជនរងផលប៉ះពាល់ដោយសារមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាចសាហាវផ្សេងៗ
- អនុវត្តកម្មវិធីអភិវឌ្ឍគ្រួសារល្អ ការចិញ្ចឹមកូនបែបវិជ្ជមាន ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ដោយប្រមូលផ្តុំលើ ការសិក្សានិងរៀបចំគោលនយោបាយជាតិ ស្តីពីការគាំពារគ្រួសារ
- បន្តរៀបចំអនុក្រឹត្យស្តីពីក្រមសីលធម៌សម្រាប់កម្លាំសេវាសង្គម និងផែនការយុទ្ធសាស្ត្រជាតិស្តីពីកម្លាំងសេវាសង្គមនៅកម្ពុជា
- បន្តផ្តល់សេវាការពារផ្លូវច្បាប់ដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងរំលោភផ្លូវភេទ ការប្រឹក្សាយោបល់ ការបញ្ជូនទៅស្តារនីតិសម្បទា និងការបណ្តុះបណ្តាលវិជ្ជាជីវៈដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងរំលោភផ្លូវភេទ មុនធ្វើសមាហរណកម្ម និងការតាមដានបន្ត
- ទទួល និងធ្វើមាតុភូមិនិវត្តជនរងគ្រោះដោយអំពើជួញដូរមនុស្សដោយគ្មានការមាក់ងាយ និងរើសអើង
- គ្រប់គ្រងទិន្នន័យជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការជួយគាំពារ និងស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរ។

**អនុកម្មវិធីទី១.២.ការអភិវឌ្ឍសុខុមាលភាពកុមារ និងយុវនីតិសម្បទា**

- បន្តត្រួតពិនិត្យ និងវាយតម្លៃគុណភាពសេវាដែលបានផ្តល់សេវាដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តមុខងារដែលបានផ្ទេរ
- បន្តពង្រឹងប្រព័ន្ធ និងគុណភាពសេវាកិច្ចការពារកុមារ ដោយប្រមូលផ្តុំលើការបង្កើតនិងដាក់ឱ្យដំណើរការប្រព័ន្ធទិន្នន័យថ្នាក់ជាតិដើម្បីគ្រប់គ្រងទិន្នន័យកុមាររងគ្រោះនិងងាយរងគ្រោះ
- បន្តលើកកម្ពស់សមត្ថភាព និងគុណភាពនៃការគ្រប់គ្រងមណ្ឌលថែទាំកុមារ ដោយផ្តោតលើគុណភាពសេវាការគ្រប់គ្រងករណី ការធ្វើអធិការកិច្ចកន្លែង ឬមណ្ឌលថែទាំកុមារ និងការថែទាំកុមារតាមសហគមន៍ឱ្យស្របតាមគោលនយោបាយ និងបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារ
- បន្តពង្រឹងពង្រីកកម្មវិធីការបង្រួបបង្រួមគ្រួសារ ការបង្វែរ និងសមាហរណកម្មកុមារពីមណ្ឌលទៅជាការថែទាំនៅតាមគ្រួសារនិងសហគមន៍ រួមទាំង ការថែទាំដោយឪពុកម្តាយធម៌ ការថែទាំដោយសាច់ញាតិ និងសុំកូនក្នុងប្រទេស
- សម្របសម្រួល និងតាមដានការអនុវត្តផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ
- តាមដានការអនុវត្តផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ
- ពង្រឹងប្រព័ន្ធពិនិត្យតាមដាន និងរបាយការណ៍ស្តីពីស្ថានភាពកុមារ ដោយប្រមូលផ្តុំលើ ការអនុវត្តគោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ ផែនការអនុវត្តគោលនយោបាយជាតិ ស្តីពីប្រព័ន្ធកិច្ចការពារកុមារ ផែនការ

សកម្មភាពដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ សំដៅលើកកម្ពស់សិទ្ធិ និងឧត្តមប្រយោជន៍របស់កុមារ
- បន្តផ្សព្វផ្សាយអនុសញ្ញា ស្តីពីសិទ្ធិកុមារ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធសិទ្ធិនិងការការពារកុមារ និងការពង្រឹងសមត្ថភាពមន្ត្រីរដ្ឋាភិបាលនិងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលឱ្យបានទូលំទូលាយ
- បន្តអនុវត្តគម្រោង "យុទ្ធនាការផ្សព្វផ្សាយ ស្តីពីផលប៉ះពាល់ដោយសារការប្រែប្រួលអាកាសធាតុមកលើស្ត្រី និងកុមារក្នុងតំបន់អាស៊ាន"
- អនុវត្តកាតព្វកិច្ចក្នុងនាមជាសមាជិកនៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ តាមរយៈការរៀបចំរបាយការណ៍ជាតិ ស្តីពីការអនុវត្តសិទ្ធិកុមារ របាយការណ៍ ស្តីពីការអនុវត្តពិធីសារបន្ថែម និងការរៀបចំទិវាកុមារអន្តរជាតិ ១មិថុនា និងទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២មិថុនា
- អនុវត្តការងារសុំកូនអន្តរប្រទេសដោយជានាឧត្តមប្រយោជន៍ និងការពារសិទ្ធិជាមូលដ្ឋានរបស់កុមារ ដោយប្រមូលផ្តុំលើការផ្តល់ការអនុញ្ញាតដល់ទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលមានវិជ្ជាជីវៈ និងក្រមសីលធម៌ក្នុងការធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេស ការផ្សព្វផ្សាយនិងការបណ្តុះបណ្តាល ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ស្តីពីសុំកូនអន្តរប្រទេសដល់អ្នកពាក់ព័ន្ធ
- ផ្តល់សេវាស្តារនីតិសម្បទាអនីតិជនដែលទំនាស់នឹងច្បាប់ តាមរយៈការដាក់ឱ្យដំណើរការមណ្ឌលយុវនីតិសម្បទា និងការទទួលអនីតិជនទំនាស់នឹងច្បាប់
- រៀបចំកម្មវិធីបណ្តុះបណ្តាលបំណិនជីវិតនិងជំនាញវិជ្ជាជីវៈដល់អនីតិជនក្នុងមណ្ឌលយុវនីតិសម្បទា
- រៀបចំនិងដាក់ឱ្យអនុវត្តនូវគោលការណ៍សម្រាប់ការអនុវត្តផែនការបង្វែរ និងរចនាសម្ព័ន្ធភ្នាក់ងារសង្គមកិច្ចពាក់ព័ន្ធនឹងយុត្តិធម៌អនីតិជន
- បន្តសហការជាមួយពន្ធនាគារផ្តល់សេវាសង្គមកិច្ចគាំពារដល់កុមារតាមម្តាយក្នុងពន្ធនាគារ
- ផ្តល់សេវាស្តារនីតិសម្បទាជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន តាមរយៈការទទួល ព្យាបាល បន្សាបស្តារនីតិសម្បទា និងបណ្តុះបណ្តាលវិជ្ជាជីវៈដល់ជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀននៅក្នុងមណ្ឌល និងលើកទឹកចិត្តការព្យាបាលនិងស្តារនីតិសម្បទាជនរងគ្រោះដែលប្រើប្រាស់បំពានសារធាតុញៀននៅតាមសហគមន៍ ដោយមានការចូលរួមទទួលខុសត្រូវ របស់ឪពុកម្តាយនិងសាច់ញាតិ និងចូលរួមតាមដានករណីអ្នកដែលបានសមាហរណកម្មទៅសហគមន៍វិញ។

**អនុកម្មវិធីទី១.៣.ការអភិវឌ្ឍសុខុមាលភាពជនពិការ**

- បន្តធ្វើបច្ចុប្បន្នភាពទិន្នន័យជនពិការ តាមបែបគំរូសង្គម និងសិទ្ធិជាមូលដ្ឋាន ដើម្បីគ្រប់គ្រងស្ថិតិជនពិការឱ្យបានច្បាស់លាស់ និងបន្តផ្តល់របបឧបត្ថម្ភជនពិការក្រីក្រនៅតាមសហគមន៍
- បន្តបណ្តុះបណ្តាលវិជ្ជាជីវៈនិងបង្កើតមុខរបរដល់ជនពិការ
- បន្តពិនិត្យ និងវាយតម្លៃ និងចុះបញ្ជិកាជូនក្រុមហ៊ុន រោងចក្រ សហគ្រាស
- សម្របសម្រួលនិងជំរុញឱ្យក្រសួង ស្ថាប័នរដ្ឋ និងសហគ្រាសឯកជនអនុវត្តកាតព្វកិច្ចទទួលជនពិការចូលបម្រើការងារ និងរៀបចំលក្ខណៈងាយស្រួល សម្រាប់ជនពិការបំលាស់ទី និងលើកទឹកចិត្តចលនាកីឡា សិល្បៈរបស់ជនពិការ
- ពង្រឹងការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការ ច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ យុទ្ធសាស្ត្រជាតិស្តីពីពិការភាព និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត តាមរយៈ ការដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ស្តីពីពិការភាព ២០១៩-២០២៣ ការធ្វើវិសោធនកម្មច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ ការផ្តល់សេវាផ្លូវច្បាប់សម្រាប់ជនពិការដោយសហការជាមួយស្ថាប័នតុលាការ មន្ត្រីយុត្តិធម៌ និងបុគ្គលិកពន្ធនាគារ
- រៀបចំរបាយការណ៍នៃការអនុវត្តអនុសញ្ញា ស្តីពីសិទ្ធិជនពិការ និងពិធីសារបន្ថែម
- ពង្រឹងយន្តការតាមដាន ត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តអនុសញ្ញា ស្តីពីសិទ្ធិជនពិការ
- រៀបចំទិវាជនពិការជាតិ អន្តរជាតិ និងទិវាផ្សេងៗពាក់ព័ន្ធជនពិការ ការអនុវត្តស្តង់ដាអប្បបរមានៃការបង្កលក្ខណៈងាយស្រួលហេដ្ឋារចនាសម្ព័ន្ធរូបវន្ត មធ្យោបាយធ្វើដំណើរ និងទំនាក់ទំនងសម្រាប់ជនពិការ ការបញ្ជ្រាបការយល់ដឹងអំពីសមត្ថភាពបើកបរនិងផ្តល់ប័ណ្ណបើកបរសម្រាប់ជនពិការ។

**អនុកម្មវិធីទី១.៤.ការអភិវឌ្ឍសុខុមាលភាពមនុស្សចាស់**

- បន្តផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់សមាគមមនុស្សចាស់ និងការងារមនុស្សវ័យចាស់សកម្ម ព្រមទាំងពង្រឹងសមត្ថភាពគណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់និងអនុគណៈកម្មាធិការដើម្បីមនុស្សចាស់ថ្នាក់រាជធានី ខេត្ត
- រៀបចំនិងអនុវត្តផែនការសកម្មភាព ២០២១-២០២៥ នៃគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ ២០១៧-២០៣០
- ដាក់ឱ្យដំណើរការមជ្ឈមណ្ឌលជាតិគាំពារមនុស្សវ័យចាស់ សំដៅបណ្តុះបណ្តាលវិជ្ជាជីវៈថែទាំមនុស្សចាស់សម្រាប់អ្នកថែទាំ អ្នកធ្វើកិច្ចការសង្គម និងអ្នកស្ម័គ្រចិត្ត។

**អនុកម្មវិធីទី១.៥.ការអភិវឌ្ឍសុខុមាលភាពអតីតយុទ្ធជន**

- បន្តបង្កើតគណៈកម្មការអភិវឌ្ឍន៍សហគមន៍អតីតយុទ្ធជនឃុំ សង្កាត់ និងការបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីនីតិវិធីប្រមូលទិន្នន័យពីស្ថានភាពជីវភាព និងតម្រូវការរបស់អតីតយុទ្ធជននិងគ្រួសារ នៅតាមឃុំ សង្កាត់
- សម្របសម្រួលការងារសមាគមអតីតយុទ្ធជននៅថ្នាក់ឃុំ សង្កាត់ ដោយសហការយ៉ាងជិតស្និទ្ធជាមួយសមាគមអតីតយុទ្ធជនកម្ពុជា ដើម្បីពង្រឹងការអនុវត្តបេឡាមរណសង្គ្រោះ។

**កម្មវិធីទី២.ការបង្កើនប្រសិទ្ធភាពប្រព័ន្ធសន្តិសុខសង្គម និងផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាជនពិការ**

**អនុកម្មវិធីទី២.១.ការបង្កើនប្រសិទ្ធភាពសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល**

- ផ្តល់របបសន្តិសុខសង្គមជូនសិទ្ធិវន្តនៃ ប.ជ.ស. តាមរយៈ ការបើកផ្តល់របបសន្តិសុខសង្គមជូននិវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងអ្នកនៅក្នុងបន្ទុក បានទាន់ពេលវេលា
- សហការជាមួយបេឡាជាតិរបបសន្តិសុខសង្គម ប.ស.ស. ដើម្បីផ្តល់សេវាធានារ៉ាប់រងសុខភាពសម្រាប់អតីតមន្ត្រីរាជការស៊ីវិល
- បន្តបើកផ្តល់ប្រាក់ឧបត្ថម្ភដល់គ្រួសារសពនិវត្តជន និងសពជនបាត់បង់សម្បទាវិជ្ជាជីវៈ និងបន្តផ្ទេរសិទ្ធិជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈដែលមានជំងឺមិនអាចទៅបើកប្រាក់សោធនប្រចាំខែនៅតាមធនាគារ។

**អនុកម្មវិធីទី២.២.ការបង្កើនប្រសិទ្ធភាពសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន និងគ្រួសារ**

- បន្តបើកផ្តល់របបសន្តិសុខសង្គមជូនអតីតយុទ្ធជននិងអ្នកនៅក្នុងបន្ទុក និងប្រាក់គោលនយោបាយមរណភាពជូនដល់គ្រួសារអតីតយុទ្ធជនឱ្យបានទាន់ពេលវេលា
- បន្តធ្វើបច្ចុប្បន្នភាពអតីតយុទ្ធជន និងការចេញលិខិតផ្ទេរសិទ្ធិបើកប្រាក់របបសន្តិសុខសង្គមប្រចាំខែជូនអតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជន
- បន្តកែសម្រួលរបបសន្តិសុខសង្គម កាត់បន្ថយគម្លាតនៃរបបសោធនរបស់នគរបាលជាតិ និងយោធិននៃកងយោធពលខេមរភូមិន្ទ និងការបង្កើនប្រាក់របបសន្តិសុខសង្គមជូនអតីតយុទ្ធជន និងអ្នកនៅក្នុងបន្ទុក។

**អនុកម្មវិធីទី២.៣.ការបន្តនិរន្តរភាពការផ្តល់សេវាស្តារលទ្ធភាពពលកម្មជូនជនពិការ**

- បន្តផ្តល់សេវាស្តារលទ្ធភាពពលកម្មគ្រប់ប្រភេទជូនជនពិការ ក្នុងនោះមាន ការផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទា ការផ្តល់សេវាស្តារលទ្ធភាពពលកម្មវេជ្ជសាស្ត្រ ការផ្តល់សេវាតាមសហគមន៍សម្រាប់ជនពិការ និងការផលិតឧបករណ៍សិប្បនិម្មិត និងឈើច្រត់
- កៀរគរប្រភពធនធានថវិកាសម្រាប់និរន្តរភាពសេវាស្តារលទ្ធភាពពលកម្មជូនជនពិការ។ ការប្រមូលភាគទានប្រាក់ពិន័យអន្តរការណ៍ចំពោះស្ថាប័ននានា និងនីតិបុគ្គលដែលមិនបានបំពេញកាតព្វកិច្ច ដូចមានចែងក្នុងច្បាប់ ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ
- បន្តពង្រីកការដាក់ហិបមូលនិធិជនពិការនៅតាមរាជធានី ខេត្ត ការផ្តល់សេវាព្យាបាលដោយចលនាដោយបង់ប្រាក់ និងការសហប្រតិបត្តិការជាមួយអង្គការដៃគូនានា
- ផ្តល់របបគោលនយោបាយឧបត្ថម្ភដល់ជនពិការ ដោយបន្តផ្តល់របបគោលនយោបាយថ្លៃធ្វើដំណើរ និងអាហារដល់ជនពិការដែលមកទទួលសេវាព្យាបាលនៅតាមមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្ម និងបន្តបើកផ្តល់របបគោលនយោបាយថែទាំសុខភាពជូនជនពិការក្រីក្រនៅសហគមន៍

- ផ្តល់ការគាំទ្រលើជីវភាពដល់ជនពិការក្រីក្រតាមរយៈការសាងសង់ផ្ទះជូន និងផ្តល់ប្រាក់កម្ចីសម្រាប់អភិវឌ្ឍមុខរបរ។

**កម្មវិធីទី៣.ការពង្រឹងសមត្ថភាពស្ថាប័ននិងអភិវឌ្ឍភាពជាដៃគូ**

**អនុកម្មវិធីទី៣.១.ការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងភាពជាដៃគូ**

- បន្តពង្រឹងការគ្រប់គ្រងមន្ត្រីរាជការ តាមរយៈ ការអនុវត្តច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល បទបញ្ជាផ្ទៃក្នុង និងរបៀបរបបធ្វើការឱ្យបានហ្មឺងម៉ាត់
- លើកទឹកចិត្តមន្ត្រីគ្រប់លំដាប់ថ្នាក់ តាមរយៈការដំឡើង ឋានៈ តួនាទី ឋានន្តរស័ក្តិ ថ្នាក់ ប្រាក់បំណាច់មុខងារ និងប្រាក់បំណាច់ផ្សេងៗ
- បន្តបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីគ្រប់លំដាប់ថ្នាក់
- ពង្រឹងការងារផែនការ និងផ្សព្វផ្សាយ តាមរយៈ ការរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ និងការផ្សព្វផ្សាយលទ្ធផលការងារដែលសម្រេចបាន
- បន្តអនុវត្តកម្មវិធីកំណែទម្រង់នានារបស់រដ្ឋ រួមមាន កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈ ការដាក់ឲ្យប្រើប្រាស់ពេញលេញមុខងារ FMIS ប្រព័ន្ធព្យាករណ៍សាច់ប្រាក់ CMS ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ SAMIS និងការដាក់ឲ្យប្រើប្រាស់នូវសៀវភៅគោលការណ៍ណែនាំស្តីពីការរៀបចំនិងការអនុវត្តថវិកា MoSVY-FMM ដើម្បីធានាបាននូវតម្លាភាពនិងប្រសិទ្ធភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រសួងស.អ.យ
- ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងអន្តរជាតិ ដើម្បីកៀរគរធនធានបម្រើឱ្យតម្រូវការ និងសំណូមពររបស់ជនរងគ្រោះនិងងាយរងគ្រោះគ្រប់ប្រភេទ និងពង្រឹងពង្រីកទំនាក់ទំនងសហប្រតិបត្តិការទ្វេភាគី ពហុភាគី ជាមួយបណ្តាប្រទេសនានា ក្នុងតំបន់អាស៊ាន និងសាកលលោក
- ពង្រឹងការងារអធិការកិច្ច ដោយប្រមូលផ្តុំលើ ការធ្វើអធិការកិច្ច អង្គភាព មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត លើការអនុវត្តបទបញ្ជាផ្ទៃក្នុង របៀបរបបការងារ និងការគ្រប់គ្រងវត្តមានរបស់មន្ត្រី និងការដោះស្រាយបណ្តឹងនិងវិវាទការងារជូនមន្ត្រីរាជការរបស់ក្រសួងប្រកបដោយយុត្តិធម៌
- បន្តធ្វើសវនកម្មនៅតាមអង្គភាព និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្តលើការគ្រប់គ្រងថវិកា និងទ្រព្យសម្បត្តិរដ្ឋ។

**អនុកម្មវិធីទី៣.២.ការអភិវឌ្ឍធនធានមនុស្ស**

- បន្តបណ្តុះបណ្តាលវិជ្ជាជីវៈកម្រិតថ្នាក់បរិញ្ញាបត្រ សង្គមកិច្ច សង្គមវិទ្យា កិច្ចគាំពារសង្គម គ្រប់គ្រងសាធារណៈ រដ្ឋបាលសាធារណៈ គោលនយោបាយសង្គម គោលនយោបាយសាធារណៈ អក្សរសាស្ត្រអង់គ្លេស និងវិស្វកម្មឧបករណ៍សិប្បនិម្មិតនិងរណប
- បន្តបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈជំនាញសង្គមកិច្ច និងការបណ្តុះបណ្តាលរយៈពេលខ្លីកម្រិតវិញ្ញាបនបត្រលើមុខជំនាញផ្សេងៗ
- បន្តអនុវត្តផែនការយុទ្ធសាស្ត្រសម្រាប់បណ្តុះបណ្តាលកម្លាំងសេវាសង្គម ដោយផ្តោតលើកិច្ចការពារកុមារ ឆ្នាំ ២០២១-២០២៥
- បន្តពង្រឹង និងពង្រីកសមត្ថភាពវិទ្យាស្ថានជាតិសង្គមកិច្ច តាមរយៈ ការជ្រើសរើសគ្រូបង្រៀនដែលមានសមត្ថភាព ការរៀបចំផែនការបណ្តុះបណ្តាល ការអភិវឌ្ឍកម្មវិធីសិក្សា ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងការបំពាក់បរិក្ខារសិក្សាសមរម្យ៕

ថ្ងៃចន្ទ ១៧ កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ២០២២

**រដ្ឋមន្ត្រី**

**វង សូត**